00649751

F2/2

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | |
|---|---|
| **សំណុំរឿងលេខ៖** | ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក |
| **ដាក់ទៅ៖** | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់៖** | ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ |
| **ភាគីអ្នកដាក់៖** | សហមេធាវីជាតិការពារក្ដីលោក **កាំង ហ្កេកអ៊ាវ** ហៅ "**ឌុច**" |
| **ភាសាដើម៖** | **ភាសាខ្មែរ** |

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ស្នើដោយភាគីអ្នកដាក់តម្កល់៖ **សាធារណៈ**

ចំណាត់ថ្នាក់សម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖

លក្ខន្តិកៈនៃចំណាត់ថ្នាក់៖

ការពិនិត្យចំណាត់ថ្នាក់បណ្ដោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿងនិងឯកសារ៖

ហត្ថលេខា៖

---

**ពាក្យស្នើសុំបន្ថែមភស្តុតាងថ្មីរបស់សហមេធាវីការពារក្ដីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច"**

---

| | | |
|---|---|---|
| **អ្នកដាក់ឯកសារ៖** | **អ្នកទទួលឯកសារ៖** | |
| **សហមេធាវីការពារក្ដីជនជាប់ចោទ** | **អង្គជំនុំជម្រះតុលាការកំពូល** | |
| **កាំង ហ្កេកអ៊ាវ** ហៅ "**ឌុច**" | ចៅក្រម **គង់ ស្រ៊ឹម** ប្រធាន | |
| មេធាវី **ការ សាវុត្ថ** | ចៅក្រម **Motoo NOGUCHI** | ចៅក្រម **ស៊ុំ រិទ្ធ** |
| មេធាវី **កង ឫទ្ធារី** | ចៅក្រម **សោម សិរីវឌ្ឍ** | ចៅក្រម **C.N.JAYASIINGHE** |
| | ចៅក្រម **A. KLONOWIECKA-MILART** | ចៅក្រម **យ៉ា ណារិន** |

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 02 / 2011
ម៉ោង (Time/Heure): 10 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

00649752

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក /អ.ជ.ត.ក

F2/2

**<u>សហព្រះរាជអាជ្ញា</u>**

លោកស្រី **ជា លាង**

លោក **Andrew CAYLEY**

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

| | | |
|---|---|---|
| មេធាវី គង់ ពិសី | មេធាវី Silke STUDZINSKY | មេធាវី Annie DELAHAIE |
| មេធាវី ហុង គឹមសួន | មេធាវី Martine JACQUIN | មេធាវី Elizabeth RABESANDRATANA |
| មេធាវី យុង ផានិត | មេធាវី Philippe CANNONE | មេធាវី Karim KHAN |
| មេធាវី គីម ម៉េងឃី | មេធាវី Pierre Olivier SUR | មេធាវី Fabienne TRUSSES-NAPROUS |
| មេធាវី ម៉ុច សុវណ្ណារី | មេធាវី Alain WERNER | មេធាវី Christine MARTINEAU |
| មេធាវី ទី ស្រ៊ីនណា | មេធាវី Brianne McGONIGLE | |

00649753

សំណុំរឿងលេខៈ ០០១/១៨-០៧-២០០៧-អ.វ.ត.ក /អ.ជ.ត.ក

F2/2

# មាតិកា

ទំព័រ


I. សេចក្ដីផ្ដើម ....................................... ៤

II. អំពីទំនាក់ទំនងដោយផ្ទាល់រវាងភស្ដុតាងបន្ថែមថ្មី ....................................... ៤

ក. គុកខ្មែរក្រហម ....................................... ៤

ខ. សេចក្ដីសន្និដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដាក់ជូនគណៈកម្មការជំនាញអង្គការសហប្រជាជាតិ (UN), អំពីឋានៈ និងមុខងាររបស់ ឌុច នៅស-២១ ....................................... ៥

គ. អំពីឯកសារថ្មីផ្សេងទៀតដែលភ្ជាប់ទៅនឹងសារណាបណ្ដឹងសាទុក្ខ និងភ្ជាប់ទៅនឹងការឆ្លើយតប ....................................... ៦

III. សំណើ ....................................... ៧

00649754



F2/2

## I. សេចក្ដីផ្ដើម

១. កាលពីថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១០ សហមេធាវីការពារជនជាប់ចោទបានដាក់សារណាបណ្ដឹងសាទុក្ខមួយនៅតុលាការកំពូល អ.វ.ត.ក[១] ។

២. កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ សហមេធាវីការពារជនជាប់ចោទបានដាក់ការឆ្លើយតបមួយ[២] ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០[៣] នៅតុលាការកំពូល នៃ អ.វ.ត.ក ។

៣. យោងអនុស្សរណៈអន្តរការិយាល័យ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ របស់ក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូល[៤] ។

## II. អំពីចំនាក់ចំនងដោយផ្ទាល់រវាងភស្តុតាងបន្ថែមថ្មី

### ក. គុកខ្មែរក្រហម

៤. **"គុកខ្មែរក្រហម"** ជាចំណងជើងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដែលចងក្រងដោយលោក **ផេង ពង្សរ៉ាស៊ី** មានចំនួន ៣២៨ទំព័រ ជាភាសាខ្មែរ ដែលមានមន្ទីរសន្តិសុខរហូតទៅដល់ ១៩៦ នៅទូទាំងប្រទេសកម្ពុជាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។

---

[១] សារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ ចុះថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ២០១០, ឯកសារ F14 ។

[២] ការឆ្លើយតបរបស់សហមេធាវីការពារក្ដីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ , ឯកសារ F14/4/2 ។

[៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០, ឯកសារ F14/4 ។

[៤] អនុស្សរណៈអន្តរការិយាល័យ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ របស់ក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូល , ឯកសារ F17 ។

៥. សហមេធាវីការពារក្ដីឱ្យលោក **កាំង ហ្គេកអ៊ាវ** ហៅ **"ឌុច"** សូមជំរាបបញ្ជាក់ជូនអង្គជំនុំជម្រះតុលាការកំពូលមេត្តាជ្រាបថា ឯកសារ **"គុកខ្មែរក្រហម"** ខាងលើនេះ ជាឯកសារថ្មីមួយដែលមិនមាននៅក្នុងសំណុំរឿងលេខ០០១ ពីមុនមកទេ ប៉ុន្តែសហមេធាវីការពារក្ដី បានដាក់ភ្ជាប់ទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ភ្ជាប់ក្នុង "ឧបសម្ព័ន្ធ ក"[៥] និងបានភ្ជាប់ទៅនឹងការឆ្លើយរបស់ខ្លួនចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ភ្ជាប់ក្នុង "ឧបសម្ព័ន្ធ ក"[៦] ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០[៧] ដោយឯកសារខាងលើនេះ មេធាវីការពារក្ដីជាតិ បានលើកយោងនៅពេលធ្វើសេចក្ដីថ្លែងបើកសវនាការក្នុងរឿងអង្គសេចក្ដីនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩[៨] និងនៅពេលធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់សវនាការក្នុងរឿងអង្គសេចក្ដីនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩[៩] នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខចុងជ្រោយ ពីទំព័រទី៨១ ដល់ទំព័រទី៨៣ នៃឯកសារ**"គុកខ្មែរក្រហម"** ជាភាសាខ្មែរ ។ ឯកសារ **"គុកខ្មែរក្រហម"**នេះ ក្រុមមេធាវីការពារក្ដី ទើបតែរកបានក្នុងពេលមានបណ្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ប៉ុណ្ណោះ ។

**ខ. សេចក្ដីសន្និដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដាក់ជូនគណៈកម្មការជំនាញអង្គការសហប្រជាជាតិ (UN), អំពីឋានៈ និងមុខងាររបស់ ឌុច នៅស-២១**

---

[៥] សារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ ចុះថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ២០១០(ឧបសម្ព័ន្ធ ក) ,ឯកសារ F14.2, F14.2.1 ។

[៦] ការឆ្លើយតបរបស់សហមេធាវីការពារក្ដីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ (ឧបសម្ព័ន្ធ ក) , ឯកសារ F14/4/2.2 , F14/4/2.2.1 ។

[៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០, ឯកសារ F14/4 ។

[៨] ប្រតិចារឹកចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ , ឯកសារ E1/6.1 , ERN 00302003, ERN 00302005(ភាសាខ្មែរ) ។

[៩] ប្រតិចារឹកចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ,ឯកសារ E1/82.1, ERN 00407948, ERN 00407950(ភាសាខ្មែរ) ។

៦. សេចក្តីសន្និដ្ឋានរបស់ **DC-Cam** ដែលបានដាក់ជូនគណៈកម្មការជំនាញរបស់ UN ដែលមានចំណងជើងថា "The selected 31 Biographies of Khmer Rough Leaders and others, Prepared for The UN Commision of Experts August-September, 1998" ក្នុងនោះក៏មានភ្ជាប់នូវសេចក្តីសន្និដ្ឋានអំពីឋានៈ និងមុខងាររបស់ **កាំង ហ្គេកអ៊ាវ** ហៅ **"ឌុច"** ដែលជាសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ នៃ **DC-Cam** ធ្វើជូនគណៈកម្មការជំនាញការ UN ដើម្បីធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

៧. សហមេធាវីការពារក្តី ក៏សូមជំរាបបញ្ជាក់ជូនអង្គជំនុំជម្រះតុលាការកំពូលមេត្តាជ្រាបផងដែរថា ចំពោះឯកសារថ្មីមួយទៀត ដែលជាសេចក្តីសន្និដ្ឋានរបស់ **DC-Cam** ខាងលើ គឺគោលបំណងរបស់សហមេធាវីការពារក្តី ចង់បង្ហាញអំពីឋានៈ និងមុខងារ **ឌុច** តាមសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញពីឋានៈ និងមុខងាររបស់ **ឌុច** នៅស-២១ ដែលបានបញ្ជាក់ថាមាន **អ្នកដែលជាថ្នាក់លើរបស់ ឌុច** គឺមានចំនួន២ទំព័រ (ជាភាសាដើមអង់គ្លេស) ហើយដែលពីមុនមកពុំទាន់មាននៅក្នុងសំណុំរឿងលេខ ០០១ នៅឡើយទេ ប៉ុន្តែសហមេធាវីការពារក្តី បានដាក់ភ្ជាប់រួចហើយដែរ ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ខ្លួនចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ភ្ជាប់ក្នុង"ឧបសម្ព័ន្ធ ក"[១០] ។ ចំពោះឯកសាររបស់ **DC-Cam** ដែលមានចំណងជើងថា "The selected 31 Biographies of Khmer Rough Leaders and others, Prepared for The UN Commision of Experts August-September, 1998" នេះ ក៏ក្រុមមេធាវីការពារក្តី ទើបតែរកបានក្នុងអំឡុងពេលមានបណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ផងដែរ ។

## គ. អំពីឯកសារបន្ថែមផ្សេងទៀតដែលភ្ជាប់ទៅនឹងសារណាបណ្តឹងសាទុក្ខ និងភ្ជាប់ទៅនឹងការឆ្លើយតប

[១០] សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ ចុះថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ២០១០(ឧបសម្ព័ន្ធ ក) ,ឯកសារ F14.2, F14.2.4 ។

E242

៨. សហមេធាវីការពារក្តី សូមជំរាបជូនអង្គជំនុំជម្រះតុលាការកំពូលមេត្តាជ្រាបថា ចំពោះឯកសារថ្មី[១១] ក្រៅពីឯកសារក្នុងចំណុច "ក" និង "ខ" ខាងលើ ដែលបានភ្ជាប់ក្នុងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០[១២] និងបានភ្ជាប់ក្នុងការឆ្លើយតបរបស់សហមេធាវីការពារក្តីចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១[១៣] ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០[១៤] គោលបំណងរបស់សហមេធាវីការពារក្តី ដាក់ឯកសារថ្មីទាំងនេះគ្រាន់តែទុកលើកឡើងដើម្បីធ្វើការប្រៀបធៀប និងពន្យល់បកស្រាយឱ្យកាន់តែច្បាស់លាស់ ក្នុងពេលសវនាការនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល និងដើម្បីជាមូលដ្ឋានសំរាប់ឱ្យអង្គជំនុំជម្រះធ្វើការពិចារណាមុននឹងធ្វើសេចក្តីសំរេចចេញជាសាលដីកាតែប៉ុណ្ណោះ ។

## III. សំណើ

៩. សុំបញ្ចូលភស្តុតាងបន្ថែមក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧ អ.វ.ត.ក/អ.ជ.ត.ក នូវ:

**ក. "គុកខ្មែរក្រហម"** ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា **(DC-Cam)** ដែលចងក្រងដោយលោក **ផេង ពង្សរ៉ាស៊ី** មានចំនួន ៣២៨ទំព័រ ជាភាសាខ្មែរ ។

---

[១១] ឯកសារស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ២ ខែកុម្ភៈ ឆ្នាំ២០០០ ទំព័រ ៥៣(ភាសាខ្មែរ) ទំព័រ ៤៣ (ភាសាអង់គ្លេស) , ឯកសារ F14.2.2 ។ ប្រជុំរឿងព្រេងខ្មែរ ភាគ ៣ បោះពុម្ព ឆ្នាំ២០០១ ទំព័រ ១៣៧-១៤៤ (ភាខ្មែរដើម), ឯកសារ F14.2.3 ។ រចនាសម្ព័ន្ធគ្រប់គ្រងបញ្ជាពីលើ ស-២១ "គុកសម្ងាត់ឃោធា" ហៅ គុកទួលស្លែង របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ពីខែ មីនា ១៩៧៦ ដល់ថ្ងៃទី១៥ សីហា ១៩៧៧ និង ពីថ្ងៃទី១៥ សីហា ១៩៧៧ ដល់ថ្ងៃទី០៦ មករា ១៩៧៩ (ភាសាខ្មែរ/អង់គ្លេស), ឯកសារ F14.2.5 ។ ប្រកាសរបស់ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការគ្រប់គ្រងពន្ធនាគារ លេខ ២១៧ ប្រ.ក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨ , ចំនួន ២៦ទំព័រ (ភាសាដើមខ្មែរ), ឯកសារ F14/4/2.2.2 ។

[១២] សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ ចុះថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ២០១០, ឯកសារ F14 ។

[១៣] ការឆ្លើយតបរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ , ឯកសារ F14/4/2 ។

[១៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០, ឯកសារ F14/4 ។

00649758



F242

**ខ.** សេចក្តីសន្និដ្ឋានរបស់ **DC-Cam** ដែលបានដាក់ជូនគណៈកម្មការជំនាញរបស់ UN ដែលមានចំណងជើងថា “The selected 31 Biographies of Khmer Rough Leaders and others, Prepared for The UN Commision of Experts August-September, 1998” ។

## សូមរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | | |
|---|---|---|---|
| ២៥-០២-២០១១ | សហមេធាវីជាតិ<br>មេធាវី **ការ សាវុត្ថ**<br>មេធាវី **កង ឫទ្ធារី** | ភ្នំពេញ | [signature]<br>[signature] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |